

## ជម្រាបសួរ មិត្តភក្តិទាំងអស់គ្នា !

ខ្ញុំឈ្មោះ ស្ទូរី ។ ខ្ញុំរស់នៅតួកម៉េនីស្ថាន ។ វាជាប្រទេសមួយនៅអាស៊ីកណ្ដាល ។ ខ្ញុំចូលចិត្តអាន គូរគំនូរ និង ដេរប៉ាក់ ។ ខ្ញុំចូលចិត្តមើលផ្កាយនាពេលរាត្រីជាមួយប៉ារបស់ខ្ញុំ ។ មានតែគ្រួសារខ្ញុំ និង ខ្ញុំប៉ុណ្ណោះដែលជាសមាជិកសាសនាចក្រក្នុងប្រទេសនេះទាំងមូល !

# ដំណើររឿងអំពី ស្ទូរី

ដោយ ជីល ហាកយីង
ទស្សនាវដ្ដីសាសនាចក្រ

### ការអធិស្ឋានសម្រាប់មីស៊ី

*ថ្ងៃមួយបន្ទាប់ពីមានព្យុះមួយដ៏ខ្លាំង មិត្តភក្តិខ្ញុំឈ្មោះ មីស៊ី បានបាត់ឆ្មារបស់នាង ។ យើងបានរកមើលវាសព្វទីកន្លែង ប៉ុន្តែពុំអាចរកវាឃើញឡើយ ។ ខ្ញុំបាននិយាយថា យើងអាចអធិស្ឋាន ។ មិត្តភក្តិរបស់ខ្ញុំពុំចេះអធិស្ឋានឡើយ ដូច្នេះខ្ញុំបានបង្ហាញពួកគេ ។ យើងទាំងអស់គ្នាបានលុតជង្គង់ចុះ យើងម្នាក់ៗបានអធិស្ឋានរៀងៗខ្លួន ។ បន្ទាប់មក ពួកយើងបានក្រោកឡើង ហើយចាប់ផ្ដើមក្រឡេកមើលម្ដងទៀត ។ មានក្មេងស្រីម្នាក់បានរត់មក ហើយប្រាប់ថានាងបានឃើញមីស៊ីហើយ ! ខ្ញុំសប្បាយចិត្ត ដែលខ្ញុំអាចចែកចាយផ្នែកមួយនៃដំណឹងល្អជាមួយមិត្តរបស់ខ្ញុំ ។*







### យើងរៀនពីគ្នាទៅវិញទៅមក

*បងស្រីរបស់ខ្ញុំ សារ៉ាយ ហើយនឹងខ្ញុំបានចូលរៀនជាមួយក្មេងៗជាច្រើនមកពីប្រទេសជាច្រើន ។ យើងចូលចិត្តរៀនពីគ្នាទៅវិញទៅមក ហើយមានភាពសប្បាយរីករាយ ។*







### វត្ថុកែច្នៃដោយដៃ និង ភាពរីករាយ

*សារ៉ាយ និង ខ្ញុំបានអញ្ជើញមិត្តភក្តិរបស់យើងមកលេងជាមួយយើង ។ យើងបានលាបថ្នាំ ធ្វើវត្ថុកែច្នៃដោយដៃ និង ញ៉ាំអាហារនៅខាងក្រៅ ។ នៅពេលបុណ្យគ្រីស្ទម៉ាស់ យើងមានការសម្ដែងដ៏ធំមួយជាមួយមិត្តភក្តិជិតខាងរបស់យើង ។*





### ព្រះវិហារនៅឯផ្ទះ

*ដោយសារមានតែគ្រួសារយើងជាសមាជិកសាសនាចក្រ នោះយើងមានព្រះវិហារនៅផ្ទះរបស់យើង ។ យើងមានការប្រជុំសាក្រាម៉ង់ ច្រៀងចម្រៀង ពេលវេលាចែកចាយ និង មេរៀនថ្នាក់បឋមសិក្សា ។ ខ្ញុំបានលេងព្យាណូពេលច្រៀងចម្រៀង ។*

### សូមផ្ញើស្នាមបាតជើងរបស់ប្អូនៗមកពួកយើង

តើប្អូនៗធ្វើតាមព្រះយេស៊ូវ ដោយការឈររឹងមាំយ៉ាងដូចម្ដេច ? សូមគូសស្នាមបាតជើងរបស់ប្អូនៗ ហើយផ្ញើរឿង និងរូបថតរបស់ប្អូនៗមកកាន់យើងខ្ញុំ ព្រមជាមួយនឹងការអនុញ្ញាតពីឪពុកម្ដាយរបស់ប្អូនៗមកជាមួយផងដែរ ។ សូមផ្ញើវាមកតាមរយៈគេហទំព័រ liahona.lds.org ( សូមចុច « Submit an Article » ) ឬ ដោយផ្ញើអ៊ីម៉ែលទៅ liahona@ldschurch.org ។